# ការប្រកួតពានរង្វាន់យុវជនគាំទ្រសិទ្ធិមនុស្ស



ការប្រកួតពានរង្វាន់យុវជនគាំទ្រសិទ្ធិមនុស្ស

## ឱកាសសម្រាប់យុវជន ការប្រកួតពានរង្វាន់យុវជនគាំទ្រសិទ្ធិមនុស្ស

តើយុវជនសង្កេតឃើញមានបញ្ហា ឬក្តីព្រួយបារម្ភចំពោះអ្វីមួយ នៅក្នុងសហគមន៍ ឬសង្គមរបស់ខ្លួនដែរ ឬទេ?

តើយុវជន យុវតីយើងចង់ឲ្យស្ថាប័នរដ្ឋ ឬអ្នកដែលពាក់ព័ន្ធជួយអន្តរាគមន៍ ឬដោះស្រាយ ចំនុចដែលយុវជនសង្កេតឃើញមានបញ្ហា ឬមានក្តីព្រួយបារម្ភនេះដែរ ឬទេ?

តើយុវជនមានគំនិតក្នុងការធ្វើការជាមួយ ឬជម្រុញឲ្យស្ថាប័ននយោបាយ ស្ថាប័នរដ្ឋនានា ឬអាជ្ញាធរមូលដ្ឋាន ឬជាតិ ដោះស្រាយបញ្ហា ឬក្តីព្រួយបារម្ភ ដែលខ្លួនឃើញមាននៅសហគមន៍របស់ខ្លួន ឬនៅក្នុងសង្គម ឬទេ?

តើយុវជនចង់អនុវត្តនូវគំនិតរបស់ខ្លួនដែលបានគិត ឬស្រមៃនោះដែរ ឬទេ?

## នៅចាំអីទៀត

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំ** កម្ពុជា (UNOHCHR) សហការជាមួយ **សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា** (CIYA) **អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា** (CRC-Cambodia) **អង្គការស្ម័គ្រចិត្ត ដើម្បីសង្គម** (CVS) **សមាគមបណ្តាញយុវជនកម្ពុជា** (CYN) **អង្គការក្រុមប្រឹក្សាយុវជនកម្ពុជា** (YCC) ក្រោមការឧបត្ថម្ភមូលនិធិដោយ **សហភាពអឺរ៉ុប** សហការរៀបចំ **ការប្រកួតពានរង្វាន់យុវជនគាំទ្រសិទ្ធិមនុស្ស** ដើម្បីបង្ហាញការទទួលស្គាល់ចំពោះយុវជនដែលបាន ឬនឹងលើកកម្ពស់ការគោរពសិទ្ធិមនុស្ស តាមរយៈសកម្មភាព ឬយុទ្ធនាការនានា ដែលជម្រុញ ឬធ្វើការជាមួយស្ថាប័ននយោបាយ ស្ថាប័នរដ្ឋនានា ឬអាជ្ញាធរមូលដ្ឋាន ឬជាតិ ឲ្យដោះស្រាយបញ្ហា ក្តីកង្វល់ ឬបង្កើតគោលនយោបាយនានា នៅក្នុងសហគមន៍ ឬសង្គម។

ប្រសិនបើយុវជនចាប់អារម្មណ៍ក្នុងការចូលរួមក្នុងការប្រកួតប្រជែងនេះ សូមអានព័ត៌មានអំពីការប្រកួតប្រជែងនេះ ហើយបំពេញទម្រង់ប្រកួតប្រជែងដែលមានភ្ជាប់មកជាមួយ និងផ្ញើមកកាន់អ៊ីមែល psok@ohchr.org ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង តាមរយៈអ៊ីមែល៖ psok@ohchr.org

បទបង្ហាញជាសាធារណៈ ដើម្បីពន្យល់បន្ថែមទាក់ទងចម្ងល់ ឬសំណួរនឹងត្រូវធ្វើឡើងចំនួនពីរដង គឺលើកទី១ នៅថ្ងៃទី២១ និងលើកទី២ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ នៅការិយាល័យ OHCHR។ អ្នកចាប់អារម្មណ៍ចូលរួមក្នុងកម្មវិធីនេះ សូមមេត្តាចុះឈ្មោះជាមុន តាមតំណរនេះ៖

https://www.surveymonkey.com/r/WFVCZ79

## ១. អំពីការប្រកួតប្រជែង

**ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំ** កម្ពុជា (UNOHCHR) សហការជាមួយ **សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា** (CIYA) **អង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា** (CRC-Cambodia) **អង្គការស្ម័គ្រចិត្ត ដើម្បីសង្គម** (CVS) **សមាគមបណ្ដាញយុវជនកម្ពុជា** (CYN) **អង្គការក្រុមប្រឹក្សាយុវជនកម្ពុជា** (YCC) ក្រោមការឧបត្ថម្ភមូលនិធិដោយ **សហភាពអឺរ៉ុប** សហការរៀបចំការប្រកួតការប្រកួតពានរង្វាន់យុវជនគាំទ្រសិទ្ធិមនុស្ស ដើម្បីបង្ហាញការទទួលស្គាល់ចំពោះយុវជនដែលបាន ឬនឹងលើកកម្ពស់ការគោរពសិទ្ធិមនុស្ស តាមរយៈសកម្មភាពចូលរួមនៅក្នុងសហគមន៍ ឬសង្គមរបស់ខ្លួន។

ការប្រកួតប្រជែងនេះនឹងធ្វើឲ្យយុវជន អាចបង្ហាញជាសាធារណៈ អំពីគំនិតផ្តួចផ្តើម សកម្មភាព ឬយុទ្ធនាការរបស់ខ្លួន និងភាពជោគជ័យរបស់ពួកគេជាសាធារណៈ។

## ២. គោលបំណង

- ដើម្បីបង្ហាញការទទួលស្គាល់ការចូលរួមរបស់យុវជនក្នុងការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា
- ដើម្បីបង្កើនការយល់ដឹងរបស់សាធារណៈជន ជាពិសេសយុវជនអំពីសិទ្ធិរបស់ពួកគេក្នុងការចូលរួមកិច្ចការសាធារណៈរបស់រដ្ឋ (នៅកម្រិតមូលដ្ឋាន ឬជាតិ)

## ៣. លក្ខខណ្ឌសម្រាប់ការចូលរួមប្រកួតប្រជែង

- បេក្ខជនត្រូវតែជាពលរដ្ឋកម្ពុជា
- បេក្ខជនដែលដាក់ពាក្យប្រកួតប្រជែងត្រូវតែធ្វើឡើងជាក្រុម (យ៉ាងតិចមានសមាជិក២រូប)
- បេក្ខជនទាំងអស់ត្រូវមានអាយុចន្លោះពី១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ (កើតចន្លោះឆ្នាំ១៩៨៩ ដល់ឆ្នាំ ២០០៤)
- សកម្មភាព ឬយុទ្ធនាការ ត្រូវតែធ្វើឡើងនៅរាជធានីភ្នំពេញ
- សកម្មភាព ឬយុទ្ធនាការគឺដាច់ខាតធ្វើឡើង ដើម្បីធ្វើការជាមួយ ឬជម្រុញឲ្យស្ថាប័ននយោបាយស្ថាប័នរដ្ឋនានា ឬអាជ្ញាធរមូលដ្ឋាន ឬជាតិ ដោះស្រាយបញ្ហា ក្តីកង្វល់ ឬគោលនយោបាយនៅសហគមន៍របស់ខ្លួន ឬនៅក្នុងសង្គម
- សមាជិកនៃក្រុមយ៉ាងតិច១រូប មានបទពិសោធន៍ក្នុងការដឹកនាំ ឬចូលរួមក្នុងសកម្មភាពដែលមានគោលបំណងដោះស្រាយបញ្ហាសហគមន៍ ឬសង្គមដោយមានការចូលរួមពីមន្ត្រីនយោបាយ អាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរជាតិ ឬស្ថាប័នរបស់រដ្ឋផ្សេងៗ។

## ៤. ដំណើរការនៃការប្រកួតប្រជែង និងពានរង្វាន់

- ការប្រកួតប្រជែងនេះ ត្រូវផ្សព្វផ្សាយជាសាធារណៈ ហើយចាប់ផ្តើមទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង ១៧.០០។
- បេក្ខជនដែលចាប់អារម្មណ៍ ត្រូវបំពេញពាក្យស្នើសុំការប្រកួតប្រជែងដែលមានភ្ជាប់ជាមួយ ហើយផ្ញើរមកកាន់ការិយាល័យ OHCHR តាមរយៈអ៊ីមែល៖ psok@ohchr.org ។
- បទបង្ហាញជាសាធារណៈដើម្បីពន្យល់បន្ថែមទាក់ទងចម្ងល់ ឬសំណួរនឹងត្រូវធ្វើឡើងចំនួនពីរដង។ លើកទី១ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៩ និងលើកទី២ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ នៅការិយាល័យ OHCHR។ អ្នកចាប់អារម្មណ៍ចូលរួមក្នុងកម្មវិធីនេះ សូមមេត្តាចុះឈ្មោះជាមុនតាមតំណរនេះ៖ https://www.surveymonkey.com/r/WFVCZ79
- បេក្ខជនដែលដាក់ពាក្យមក នឹងត្រូវជ្រើសរើសតែ១០ក្រុម សម្រាប់ការសម្ភាសន៍ ដើម្បីជ្រើសរើសយក៥ ក្រុម សម្រាប់ការប្រកួតប្រជែង។
- បេក្ខជនដែលត្រូវបានជ្រើសរើសសម្រាប់ការប្រកួតប្រជែង នឹងទទួលបានការបណ្តុះបណ្តាលអំពីសិទ្ធិមនុស្ស សិទ្ធិក្នុងការចូលរួម ការធ្វើយុទ្ធនាការ ការណែនាំជាមូលដ្ឋានអំពីដំណើរការផលិតវីដេអូ។
- បេក្ខជនទាំង៥ ក្រុម ដែលត្រូវបានជ្រើសរើសសម្រាប់ការប្រកួតប្រជែងនឹងត្រូវអនុវត្តសកម្មភាព/យុទ្ធការរបស់ខ្លួន ហើយសកម្មភាព ឬយុទ្ធនាការនោះ នឹងត្រូវថតជាវីដេអូដោយក្រុមហ៊ុនវីដេអូឯកជន ដែលជួលដោយអ្នករៀបចំកម្មវិធីនេះ។ បេក្ខជន និងក្រុមហ៊ុនផលិតវីដេអូនឹងត្រូវធ្វើការរួមគ្នា ដើម្បីធានាថា សកម្មភាព/យុទ្ធនាការរបស់ខ្លួន និងការថតវីដេអូ ធ្វើទៅដោយរលូន។
- កិច្ចការបច្ចេកទេសទាក់ទងនឹងការថតវីដេអូ ការកាត់តវីដេអូ។ល។ គឺជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនវីដេអូ។ ទោះជាយ៉ាងណាក៏ដោយ បេក្ខជនក្រុមនីមួយៗជាអ្នកសម្រេចថា តើចង់បានព័ត៌មាន សកម្មភាព រូបវីដេអូ។ល។ សម្រាប់វីដេអូរបស់ក្រុមខ្លួន។
- បន្ទាប់ពីការអនុវត្តសកម្មភាព/យុទ្ធនាការរបស់ខ្លួនចប់ វីដេអូនៃសកម្មភាពរបស់ក្រុមបេក្ខជននីមួយៗនឹងត្រូវបង្ហោះលើហ្វេសប៊ុករបស់ការិយាល័យ OHCHR ដើម្បីឲ្យសាធារណៈជន ធ្វើការបោះឆ្នោត។ ក្រុមបេក្ខជននីមួយៗ អាចធ្វើយុទ្ធនាការផ្សេងៗដើម្បីផ្សព្វផ្សាយអំពីវីដេអូរបស់ខ្លួន ឬដើម្បីឲ្យសាធារណៈជនគាំទ្រវីដេអូរបស់ខ្លួន។
- អ្នករៀបចំកម្មវិធីមានការឧបត្ថម្ភជាសម្ភារៈ (មានកំណត់) សម្រាប់ក្រុមនីមួយៗក្នុងការធ្វើសកម្មភាពរបស់ខ្លួន។

- ការផ្តល់ពិន្ទុចែកជាពីរ៖ ៥០% បានពីការផ្តល់ពិន្ទុពីសាធារណៈជនទៅលើវីដេអូដែលបានផ្សាយលើហ្វេសបុករបស់ការិយាល័យ OHCHR (តាមរយៈ Like, love, etc.) និង៥០% ទៀត គឺសម្រាប់ពិន្ទុបានពីការប្រលងចំណេះដឹងស្តីពីសិទ្ធិមនុស្ស។
- លទ្ធផលនៃជ័យលាភីលេខ១ លេខ២ និងលេខ៣ នឹងត្រូវប្រកាសនៅកម្មវិធីសិទ្ធិមនុស្សនៅថ្ងៃណាមួយចន្លោះពីថ្ងៃទី៧ ដល់១០ ខែធ្នូ ឆ្នាំ២០១៩។
- ជ័យលាភីលេខ១ លេខ២ និងលេខ៣ និងទទួលបានពាន និងរង្វាន់លើកទឹកចិត្ត។ ចំណែកអ្នកចូលរួមទាំង៥ ក្រុម និងទទួលបានលិខិតបញ្ជាក់ការចូលរួម ពីអ្នករៀបចំកម្មវិធី។

## ៥. ពេលវេលានៃសកម្មភាព

| ល.រ. | សកម្មភាព | កាលបរិច្ឆេទ | ផ្សេង |
|---|---|---|---|
| ១ | ការប្រកាសទទួលពាក្យ | ថ្ងៃជូនដំណឹង ដល់ថ្ងៃទី ០៩ សីហា ២០១៩ | ឯកសារ និងពាក្យស្នើសុំមានភ្ជាប់មកជាមួយ |
| ២ | ការធ្វើបទបង្ហាញអំពីការប្រកួតប្រជែង | ២១ កក្កដា ២០១៩ | អ្នកចូលរួមត្រូវចុះឈ្មោះជាមុន |
| ៣ | ការធ្វើបទបង្ហាញអំពីការប្រកួតប្រជែង | ២៧ កក្កដា ២០១៩ | អ្នកចូលរួមត្រូវចុះឈ្មោះជាមុន |
| ៤ | ឈប់ទទួលពាក្យ | ៩ សីហា ២០១៩ វេលាម៉ោង១៧.០០ | |
| ៥ | ជូនដំណឹងដល់ក្រុមបេក្ខជនដែលត្រូវមកសម្ភាសន៍ | ១៩ សីហា ២០១៩ | |
| ៦ | ការសម្ភាសន៍ក្រុមបេក្ខជនទាំង១០ ក្រុម | ២២ដល់ ២៣ សីហា ២០១៩ | មួយក្រុមសម្ភាសន៍៤៥ នាទី |
| ៧ | ជូនដំណឹងដល់ក្រុមជោគជ័យទាំង៥ ក្រុម | ២៦ សីហា ២០១៩ | |
| ៨ | ការបណ្តុះបណ្តាលដល់ក្រុមទាំង៥ អំពីសិទ្ធិមនុស្ស ការចូលរួម និងការធ្វើយុទ្ធនាការ | ៣០ ដល់៣១ សីហា ២០១៩ | រយៈពេល ២ ថ្ងៃ |
| ៩ | ការបណ្តុះបណ្តាលដល់ក្រុមទាំង៥អំពីមូលដ្ឋាននៃដំណើរការផលិតវីដេអូ | ១ កញ្ញា ២០១៩ | មួយថ្ងៃ |
| ១០ | បេក្ខជនទាំង៥ ក្រុម បញ្ជូនផែនការសកម្មភាព និងកាលបរិច្ឆេទច្បាស់លាស់ (ក្នុងករណីមានការផ្លាស់ប្តូរ) មកកាន់អ្នករៀបចំកម្មវិធី | ៥ កញ្ញា ២០១៩ | |

| | | | |
|---|---|---|---|
| ១១ | បេក្ខជនទាំង៥ ក្រុម ជួយជាមួយក្រុមហ៊ុនផលិតវីដេអូ ដើម្បីពិភាក្សាសម្រេចទៅលើការថតវីដេអូរបស់ក្រុមនីមួយៗ | ៨ កញ្ញា ២០១៩ (ម៉ោង ៩.០០ដល់១២.០០) | មួយព្រឹក |
| ១២ | បេក្ខជនទាំង៥ ក្រុម ចាប់ផ្តើមអនុវត្តសកម្មភាព/យុទ្ធនាការរបស់ខ្លួន | ចន្លោះពីថ្ងៃទី ០៩ កញ្ញា ដល់ ២០ តុលា ២០១៩ | គ្រប់សកម្មភាព ឬ យុទ្ធនាការនានា ត្រូវបញ្ចប់ត្រឹមថ្ងៃទី២០ តុលា ២០១៩ |
| ១៣ | ការជួបជាមួយក្រុមបេក្ខជនជាមួយអ្នករៀបចំកម្មវិធី ដើម្បីចែករំលែកពីការរីកចម្រើន ឬការប្រឈមនានា | ២០ កញ្ញា ២០១៩ ម៉ោង ៩.០០ ដល់ ១២.០០ | ការជួបលើកទី១ |
| ១៤ | ការជួបជាមួយក្រុមបេក្ខជនជាមួយអ្នករៀបចំកម្មវិធី ដើម្បីចែករំលែកពីការរីកចម្រើន ឬការប្រឈមនានា | ០៤ តុលា ២០១៩ ម៉ោង ៩.០០ ដល់ ១២.០០ | ការជួបលើកទី២ |
| ១៥ | ការផុសវីដេអូរបស់ក្រុមបេក្ខជននៅលើហ្វេសប៊ុករបស់ការិយាល័យ OHCHR | ១៥ ដល់ ២៩ វិច្ឆិកា ២០១៩ | |
| ១៦ | ការធ្វើយុទ្ធនាការរបស់ក្រុមបេក្ខជនទៅលើវីដេអូរបស់ខ្លួន ដើម្បីឲ្យមានការគាំទ្រពីសាធារណៈជន | ១៥ ដល់ ២៩ វិច្ឆិកា ២០១៩ | |
| ១៧ | ការប្រលងចំណេះដឹងទាក់ទងសិទ្ធិមនុស្សសម្រាប់បេក្ខជនទាំង៥ ក្រុម នៅការិយាល័យ OHCHR | ៣០ វិច្ឆិការ ២០១៩ ម៉ោង៩.០០ ដល់ ១១.០០ | |
| ១៨ | ការជួបជាមួយបេក្ខជន ដើម្បីត្រៀមបង្ហាញខ្លួន និងទទួលពានរង្វាន់ | ០៦ ធ្នូ ២០១៩ ម៉ោង ៩.០០ ដល់១១.០០ | នៅការិយាល័យ OHCHR |
| ១៩ | ការប្រកាសលទ្ធផល និងទទួលពានរង្វាន់ | ចន្លោះពីថ្ងៃទី ៧ ដល់ ១០ ធ្នូ | អាចថ្ងៃទី៧ ឬ៨ ឬ៩ ឬ១០ ខែធ្នូ |
| ២០ | ការជួបប្រជុំដើម្បីឆ្លុះបញ្ចាំងពីគម្រោង | ២៦ ធ្នូ ២០១៩ | |

## ៦. ការវាយតម្លៃទៅលើពាក្យសុំប្រកួតប្រជែង

**សកម្មភាព/យុទ្ធនាការទាំងឡាយណាដែលមិនឆ្លើយតបទៅនឹង "លក្ខខណ្ឌសម្រាប់ការចូលរួមប្រកួតប្រជែង" នឹងមិនត្រូវយកមកពិនិត្យ និងវាយតម្លៃឡើយ។**

### ក. គោលបំណងនៃសកម្មភាព/គម្រោង/យុទ្ធនាការ (៣០%)

- គោលបំណងនៃសកម្មភាព/យុទ្ធនាការ/គម្រោងឆ្លើយតបទៅនឹងគោលបំណងនៃការប្រកួតប្រជែង
- ការសម្រេចបានលទ្ធផល/ការផ្លាស់ប្តូរ ក្នុងអំឡុងពេលធ្វើសកម្មភាព
- សកម្មភាព/យុទ្ធនាការ/សមាសភាពក្រុម ឆ្លើយតបទៅនឹងលក្ខខណ្ឌដែលបានកំណត់

### ខ. វិធីសាស្ត្រ/សកម្មភាព (៥០%)

- សកម្មភាព/យុទ្ធសាស្ត្រ/យុទ្ធនាការ ដែលនឹងធ្វើអាចនាំឲ្យសម្រេចបានគោលបំណង/លទ្ធផល/ការផ្លាស់ប្តូរ
- ការកៀងគរអ្នកដទៃអោយចូលរួមក្នុងសកម្មភាព/យុទ្ធនាការនោះ
- សកម្មភាព/យុទ្ធនាការមានការគោរព និងជួយដល់ការលើកកម្ពស់សិទ្ធិមនុស្ស
- សកម្មភាពដែលធ្វើនោះផ្តល់ផលវិជ្ជមានទាំងប្រុស ស្រី ឬភេទដទៃទៀត
- ការបង្កើត បង្កើន ឬភ្ជាប់ជាមួយបណ្តាញផ្សេងៗទៀតក្នុងការធ្វើសកម្មភាព ឬយុទ្ធនាការ
- គំនិតផ្ទៃប្រឌិតក្នុងការអនុវត្ត

### គ. សមាសភាពក្រុម (២០%)

- ក្នុងក្រុមមានសមាសភាពចម្រុះភេទ ហើយភេទនីមួយៗមានចំនួនប្រហាក់ប្រហែលគ្នា
- ក្នុងក្រុមមានសមាសភាពផ្សេងៗដូចជាជនជាតិដើមភាគតិច ឬជនពិការ
- ការតាំងចិត្តរបស់សមាជិកក្នុងក្រុម
- បទពិសោធន៍របស់សមាជិកក្នុងក្រុមសមាជិកក្នុងក្រុមជាសមាជិកបណ្តាញរបស់អង្គការ ឬបណ្តាញផ្សេងៗ